**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ :** ១៤ ភស៊ុ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការ

## ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមិនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/១០៣ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌលេខាធិការរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ១.-**

បង្កើតគណៈកម្មការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការនៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការប្រចាំការ | ជាប្រធាន |
| ២. ឯកឧត្តម | **សំ ម៉ិនណា** | អនុរដ្ឋលេខាធិការ | ជាអនុប្រធាន |
| ៣. លោក | **ពៅ ចាន់មុនីផល** | ប្រធានស្ដីទីនាយកដ្ឋានបុគ្គលិក | ជាសមាជិក |
| ៤. អគ្គនាយក ប្រធាននាយកដ្ឋាន ឬប្រធានអង្គភាពចំណុះទីស្ដីការគណៈរដ្ឋមន្ត្រី ដែលមានមន្ត្រីរាជការត្រូវតាំងស៊ប់ | | | ជាសមាជិក |
| ៥. មន្ត្រីរាជការមួយរូបដែលមានក្របខណ្ឌជាមួយគ្នា | | | ជាសមាជិក។ |

**ប្រការ២.-**

គណៈកម្មការនេះមានភារកិច្ចពិនិត្យ និងវាយតម្លៃលើសកម្មភាពការងាររបស់កម្មសិក្សាការីដែលបានបញ្ចប់រយៈពេលនៃកម្មសិក្សា ដើម្បីសម្រេច និងរៀបចំបែបបទតាំងស៊ប់ក្នុងក្របខណ្ឌជូនមន្ត្រីរាជការ។

**ប្រការ៣.-**

អនុប្រធាន និងសមាជិកនៃគណៈកម្មការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ។

**ប្រការ៤.-**

សេចក្ដីសម្រេចលេខ៣៤ សសរ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៨ ស្ដីពីការបង្កើតគណៈកម្មការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**កន្លែងទទួល :**

- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ